អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**សហចៅក្រមស៊ើបអង្កេតជាតិ**

**ជម្រាបជូន**

**លោក** Laurent Kasper Ansermet

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង**

**កម្មវត្ថុ៖** ការបញ្ឈប់ជាបន្ទាន់នូវសកម្មភាពមិនស្របច្បាប់នានា និងការយកឈ្មោះរបស់ខ្ញុំទៅពាក់ព័ន្ធនឹងសកម្មភាពទាំងនោះ

លោកចៅក្រមបម្រុង

ខ្ញុំសូមគូសបញ្ជាក់សារជាថ្មីថា ដូចដែលខ្ញុំបានលើកឡើងក្នុងលិខិតរបស់ខ្ញុំចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០១១ និងសេចក្តីប្រកាសព័ត៌មានរបស់ខ្ញុំជាបន្តបន្ទាប់ ខ្ញុំមិនដែលពិភាក្សាជាមួយលោក អំពីបញ្ហាកិច្ចនីតិវិធីណាមួយឡើយទាក់ទិនទៅនឹងសំណុំរឿង ០០៣ និង ០០៤ ហើយលោកក៏ទទួលស្គាល់ផងដែរថា ខ្ញុំមិនដែលទទួលស្គាល់អំពីសិទ្ធិអំណាចរបស់លោកក្នុងការបំពេញការងារជាចៅក្រមបម្រុងដែរ។ដូចនេះ លោកមិនអាចលើកឡើងអំពីការខ្វែងយោបល់គ្នាណាមួយរវាងលោក និងខ្ញុំនៅក្នុងការបំពេញកិច្ចនីតិវិធីឡើយ ហើយកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏មិនអនុញ្ញាតឲ្យលោកមានសិទ្ធិនៅក្នុងការបំពេញការងារជាចៅក្រមបម្រុងក្នុងបរិបទ ដែលតំណែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅទំនេរដូចនេះដែរ។ នៅក្នុងន័យនេះ អ្វីដែលលោកបាននឹងកំពុងធ្វើនាពេលកន្លងមកគឺជាសកម្មភាពមិនស្របច្បាប់ឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំសូមឲ្យលោកបញ្ឈប់ជាបន្ទាន់នូវសកម្មភាពមិនស្របច្បាប់នានារបស់លោក និងឈប់យកឈ្មោះរបស់ខ្ញុំទៅពាក់ព័ន្ធជាមួយសកម្មភាពមិនស្របច្បាប់ទាំងអស់នេះ ជាពិសេសការពាក់ព័ន្ធនូវអ្វីដែលលោកតែងតែចាត់ទុកតែម្នាក់ឯងថា ជាការខ្វែងយោបល់គ្នានោះ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២7ខែកុម្ភៈ ឆ្នាំ២០១២*

**សហចៅក្រមស៊ើបអង្កេតជាតិ**

**យូ ប៊ុនឡេង**